**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**លេខ** :..........០១៥/២០..........ក.ប/ស.ជ.ណា.ខ.ល

# សេចក្តីជូនដំណឹង
## ស្តីពី
## ការប្រើប្រាស់ប័ណ្ណអនុញ្ញាតដឹកជញ្ជូនកម្មករនិយោជិត និងការធ្វើការងារនៅក្នុងអំឡុងពេលការដាក់កំហិតលើការធ្វើដំណើរក្នុងប្រទេស ក្នុងគោលដៅបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺកូវីដ-១៩

យោងបទបញ្ជាលេខ០២ប.ប ចុះថ្ងៃទី៩ ខែមេសា ឆ្នាំ២០២០ ស្តីពីការដាក់កំហិតលើការធ្វើដំណើរក្នុងប្រទេស ក្នុងគោលដៅបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺកូវីដ-១៩ របស់រាជរដ្ឋាភិបាល ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនដល់ម្ចាស់ ឬនាយករោងចក្រ សហគ្រាស គ្រឹះស្ថាន ដែលមិនត្រូវបានកំណត់ឱ្យបិទសកម្មភាពអាជីវកម្ម, កម្មករនិយោជិត និងបុគ្គលិក, និងអ្នកបើកបរ ឬម្ចាស់មធ្យោបាយដឹកជញ្ជូនកម្មករនិយោជិត និងបុគ្គលិក ដូចខាងក្រោម៖

**ក-ចំពោះកម្មករនិយោជិត និងបុគ្គលិក**

- អ្នកប្រើប្រាស់មធ្យោបាយធ្វើដំណើរផ្ទាល់ខ្លួន និងធ្វើដំណើរតែម្នាក់ឯងត្រូវយកតាមខ្លួននូវ (១) កាតសម្គាល់កម្មករនិយោជិត ឬបុគ្គលិក, និង (២) អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬឯកសារដែលអាចបញ្ជាក់ពីទីលំនៅបច្ចុប្បន្នរបស់ខ្លួន នៅរៀងរាល់ពេលធ្វើដំណើរទៅកន្លែងធ្វើការ និងត្រឡប់មកផ្ទះ ដើម្បីបង្ហាញជូនអាជ្ញាធរមានសមត្ថកិច្ច។
- អ្នកប្រើប្រាស់មធ្យោបាយធ្វើដំណើររួមត្រូវ (១) ជិះមធ្យោបាយដែលមាន "ប័ណ្ណអនុញ្ញាតដឹកជញ្ជូនកម្មករនិយោជិត" ចេញដោយក្រសួង ឬមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, និង (២) យកតាមខ្លួននូវកាតសម្គាល់កម្មករនិយោជិត និងបុគ្គលិក នៅរៀងរាល់ពេលធ្វើដំណើរទៅកន្លែងធ្វើការ និងត្រឡប់មកផ្ទះ ដើម្បីបង្ហាញជូនអាជ្ញាធរមានសមត្ថកិច្ច។
- ត្រូវមកធ្វើការដូចថ្ងៃធម្មតានៅតាមរោងចក្រ សហគ្រាស គ្រឹះស្ថាន របស់ខ្លួន។ ក្នុងករណីមិនមកធ្វើការត្រូវចាត់ទុកជាមានកំហុសធ្ងន់ ដែលអាចប្រឈមនឹងការបញ្ឈប់ពីការងារដោយគ្មានសំណង។
- ត្រូវចូលធ្វើការងារធម្មតាតាមកន្លែងការងាររបស់ខ្លួន និងមិនត្រូវបង្កការរំខាន ឬធ្វើឱ្យរាំងស្ទះដល់ការបំពេញការងាររបស់កម្មករនិយោជិត និងបុគ្គលិកដទៃទៀត ឬចង្វាក់ផលិតកម្មរបស់រោងចក្រ សហគ្រាស គ្រឹះស្ថាន។
- មិនត្រូវចូលរួម ឬធ្វើសកម្មភាពញុះញង់ បំភិតបំភ័យ គំរាមកំហែងកម្មករនិយោជិត និងបុគ្គលិកផ្សេងទៀត បើមិនដូច្នេះ នឹងត្រូវទទួលទោសតាមច្បាប់ព្រហ្មទណ្ឌ និងច្បាប់ជាធរមានដទៃទៀត។



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៥

**ខ-ចំពោះម្ចាស់ ឬនាយករោងចក្រ សហគ្រាស គ្រឹះស្ថាន**

- ត្រូវផ្តល់បញ្ជីស្លាកលេខរថយន្ត ឬមធ្យោបាយដឹកជញ្ជូនដល់អធិការការងារ។
- ត្រូវសហការជាមួយអធិការការងារ ដើម្បីផ្តល់ "ប័ណ្ណអនុញ្ញាតដឹកជញ្ជូនកម្មករនិយោជិត" ដល់អ្នកបើកបរ (ដូចមានគំរូជូនភ្ជាប់ជាមួយ) សម្រាប់បង្ហាញជូនអាជ្ញាធរមានសមត្ថកិច្ចនៅពេលដឹកជញ្ជូនកម្មករនិយោជិត និងបុគ្គលិកទៅកន្លែងធ្វើការ និងត្រឡប់មកផ្ទះ។
- ត្រូវធានាថាកម្មករនិយោជិត និងបុគ្គលិកទាំងអស់មានកាតសម្គាល់ខ្លួន។ ក្នុងករណីបាត់ ត្រូវចេញកាតសម្គាល់ខ្លួនជូនកម្មករនិយោជិត និងបុគ្គលិកជាបន្ទាន់។
- ត្រូវបញ្ចប់សេវាដឹកជញ្ជូនជាមួយអ្នកផ្តល់សេវាដឹកជញ្ជូនកម្មករនិយោជិតណា ដែលមិនដឹកកម្មករនិយោជិត និងបុគ្គលិកទៅកន្លែងធ្វើការ និងត្រឡប់មកផ្ទះ ក្នុងអំឡុងពេលនេះ។
- ត្រូវជូនដំណឹងដល់អ្នកលក់អាហារ និងបន្តធានាផ្តល់កន្លែងលក់អាហារជាធម្មតា។
- ត្រូវបើកដំណើរការផលិតកម្ម ឬអាជីវកម្មរបស់ខ្លួនជាធម្មតា បើមិនដូច្នេះ ត្រូវចាត់ទុកថា ប្រឆាំងនឹងបទបញ្ជារបស់រាជរដ្ឋាភិបាល និងត្រូវបាត់សិទ្ធិទទួលបានការឧបត្ថម្ភពីរាជរដ្ឋាភិបាល នៅពេលព្យួរកិច្ចសន្យាការងារ ឬផ្អាកសកម្មភាពអាជីវកម្ម ឬការលើកទឹកចិត្តនានារបស់រាជរដ្ឋាភិបាល។
- ត្រូវចាត់រដ្ឋបាលឱ្យគ្រប់គ្រងបញ្ជីវត្តមានកម្មករនិយោជិត និងបុគ្គលិកឱ្យបានច្បាស់លាស់ ដើម្បីប្រគល់ជូនអធិការការងារ និងអាជ្ញាធរមានសមត្ថកិច្ច។

**គ-ចំពោះអ្នកបើកបរ ឬម្ចាស់មធ្យោបាយដឹកជញ្ជូនកម្មករនិយោជិត និងបុគ្គលិក**

- ត្រូវបន្តដឹកជញ្ជូនកម្មករនិយោជិត និងបុគ្គលិក ទៅកន្លែងធ្វើការ និងត្រឡប់មកផ្ទះដូចធម្មតា បើមិនដូច្នេះ ត្រូវចាត់ទុកថាប្រឆាំងនឹងបទបញ្ជារបស់រាជរដ្ឋាភិបាល និងត្រូវប្រឈមនឹងការបង្ខំឱ្យបញ្ចប់កិច្ចសន្យាផ្តល់សេវាដឹកជញ្ជូនកម្មករនិយោជិត និងបុគ្គលិក។
- ត្រូវមកទទួលយក "ប័ណ្ណអនុញ្ញាតដឹកជញ្ជូនកម្មករនិយោជិត" ពីរោងចក្រ សហគ្រាស គ្រឹះស្ថាន និងត្រូវដាក់បង្ហាញនៅផ្នែកខាងមុខមធ្យោបាយដឹកជញ្ជូន ដើម្បីបង្ហាញជូនអាជ្ញាធរមានសមត្ថកិច្ច។

ក្រសួងមានសេចក្តីជឿជាក់ថា ម្ចាស់ ឬនាយករោងចក្រ សហគ្រាស គ្រឹះស្ថាន ដែលមិនត្រូវបានកំណត់ឱ្យបិទសកម្មភាពអាជីវកម្ម, កម្មករនិយោជិត និងបុគ្គលិក, និងអ្នកបើកបរ ឬម្ចាស់មធ្យោបាយដឹកជញ្ជូនកម្មករនិយោជិត និងបុគ្គលិកទាំងអស់នឹងអនុវត្តតាមសេចក្តីជូនដំណឹងនេះ ប្រកបដោយប្រសិទ្ធភាពខ្ពស់។

ថ្ងៃ ព្រហស្បតិ៍ ២រោច ខែ ចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ៩ ខែ មេសា ឆ្នាំ២០២០

រដ្ឋមន្ត្រី

អ៊ិត សំហេង

**កន្លែងទទួល:**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
-ក្រសួង ស្ថាប័នពាក់ព័ន្ធ
"ដើម្បីជូនជ្រាប"
-មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី ខេត្ត
-អង្គការវិជ្ជាជីវៈគ្រប់លំដាប់ថ្នាក់
"ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
-ឯកសារ កាលប្បវត្តិ

# ប័ណ្ណអនុញ្ញាតដឹកជញ្ជូនកម្មករនិយោជិត

## ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខៈ ..........................................................................

ទំនាក់ទំនងទូរស័ព្ទលេខៈ

០១២ ៣០០ ១១៨
០១២ ៩៦៦ ៤១៦
០៩២ ៤២៤ ០៥០

**សុពលភាពចាប់ពីថ្ងៃទី១០ ដល់ថ្ងៃទី១៦ ខែមេសា ឆ្នាំ២០២០**

**សម្រាប់ចម្ងាយផ្លូវពី**..................................**ទៅ**..................................

# ប័ណ្ណអនុញ្ញាតដឹកជញ្ជូនកម្មករនិយោជិត

**មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត..............**

លេខ: ..................................................................................

ទំនាក់ទំនងទូរស័ព្ទលេខ:

០១២ ### ###
០១១ ### ###

**សុពលភាពចាប់ពីថ្ងៃទី១០ ដល់ថ្ងៃទី១៦ ខែមេសា ឆ្នាំ២០២០**

**សម្រាប់ចម្ងាយផ្លូវពី..............................ទៅ..............................**